# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Nov-2011, 14:16
CMS/CFO: Kauv Keoratanak

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ការជំទាស់របស់សហព្រះរាជអាជ្ញា ទៅនឹងបញ្ជីឯកសារដែលបានស្នើឡើងដោយភាគី សម្រាប់សវនាការរយៈពេលបីសប្ដាហ៍ដំបូង

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | នួន ជា |
| | ចៅក្រម យ៉ា សុខន | អៀង សារី |
| | ចៅក្រមJean-Marc LAVERGNE | អៀង ធីរិទ្ធ |
| | ចៅក្រម យូ ឧត្តរា | ខៀវ សំផន |
| | សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី: | មេធាវីការពារក្ដីជនជាប់ចោទ: |
| | ពេជ អង្គ | លោក សុន អរុណ |
| | Elisabeth SIMONNEAU FORT | លោក Michiel PESTMAN |
| | | លោក Victor Koppe |
| | | លោក អាង ឧត្ដម |

លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក ស សុវាន
លោក Jacques VERGÈS

# I. សេចក្តីផ្តើម

១- អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យភាគីដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរ ប្រសិនបើមានទៅនឹងឯកសារ និងវត្ថុតាងផ្សេងៗដែលបានស្នើឡើងដោយភាគីនានា ដែលនឹងត្រូវទទួលយកនៅក្នុងរយៈពេលបីសប្តាហ៍ដំបូងនៃសវនាការ[1]។ ជាការឆ្លើយតបទៅនឹងសេចក្តីបង្គាប់នេះ សហព្រះរាជអាជ្ញា សូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា សហព្រះរាជអាជ្ញា៖

(១) មិនជំទាស់នឹងការទទួលយកឯកសារណាមួយដែលបានស្នើឡើង ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារ ដាក់ជូនដោយក្រុមមេធាវីការពារក្តី អៀង សារី ឬ ខៀវ សំផន ទេ បើសិនជាឯកសារនោះ ជាឯកសារមួយថ្មីដែលបានដាក់បញ្ចូលក្នុងបញ្ជីឯកសាររបស់ អៀង សារី អាចឱ្យភាគី រកបានជាមុន ។

(២) សូមរក្សាគោលជំហររបស់ខ្លួនពាក់ព័ន្ធនឹងឯកសារ "ថ្មី" ចំនួន ប្រាំ ដែលបានស្នើឡើង ដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារដាក់ជូនដោយក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ រហូតដល់ពេលណាដែលឯកសារទាំងអស់នោះ អាចឱ្យគេរកបាន។

(៣) ផ្ទុយទៅវិញ មិនជំទាស់នឹងការទទួលយកឯកសារណាមួយដែលបានស្នើឡើង បានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារដាក់ជូនដោយមេធាវីការពារក្តី អៀង ធីរិទ្ធ ទេ (មានការដាក់បញ្ចូលឯកសារពីរច្បាប់ផ្សេងទៀត ដោយចំណាត់ប្រភេទ ជាឯកសារថ្មី ប៉ុន្តែការពិតឯកសារទាំងពីរច្បាប់នោះ មាននៅក្នុងសំណុំរឿងរួចហើយ; និង

(៤) មិនជំទាស់នឹងការទទួលយកឯកសារណាមួយដែលបានស្នើឡើង បានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារដាក់ជូនដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទេ បើសិនជាឯកសារនោះ ជាឯកសារមួយថ្មីដែលបានស្នើឡើង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលអាចឱ្យភាគីរកបានជាមុន។

---

[1] **E131/1** *អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង, ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5*; ២៥ តុលា ២០១១ (សំណៅច្បាប់ចម្លងនៃអនុស្សរណៈនេះត្រូវបានទាក់ទងគ្នាតាមអ៊ីម៉ែលជាមុនគ្រាន់ជាការគួរសមជូនភាគីនានា នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ("អនុស្សរណៈ") ។

ដើម្បីជាការងាយស្រួល បញ្ជីឯកសារ "ថ្មី" ដែលបានស្នើឡើងដោយភាគីនានា ដែលការពិត ភាគច្រើននៃបញ្ជីឯកសារទាំងនោះ មាននៅក្នុងសំណុំរឿង បានដាក់ភ្ជាប់ជាមួយនឹងការដាក់ឯកសារនេះ ជា **ឧបសម្ព័ន្ធ ក**។

២- សហព្រះរាជអាជ្ញាស្នើថា ក្នុងករណីគ្មានការជំទាស់សមហេតុផលណាមួយដែលលើកឡើងដោយភាគី អង្គជំនុំជម្រះទទួលយកជាឯកសារ ដែលជាឯកសារមិនមានការជំទាស់ពីសហព្រះរាជអាជ្ញា និងជាឯកសារដែលភាគីទាំងអស់អាចរកបាននៅពេលបច្ចុប្បន្ននេះ ទុកជាភស្តុតាង ដោយអនុលោមតាមវិធាន៨៧(២)។

## II. ប្រវត្តិនីតិវិធី

៣- នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ក្នុងអម្លុងពេលសវនាការបឋមសម្រាប់សំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីកំណត់អត្តសញ្ញាណត្រឹមថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ នូវឯកសារ និងវត្ថុតាងទាំងឡាយណាដែលខ្លួនពិចារណាថា មានការពាក់ព័ន្ធនឹងដំណាក់កាលដំបូងនៃសវនាការ (បញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការ)[2]។ នៅពេលនោះ គេពិនិត្យឃើញថាដំណាក់កាលដំបូងនៃសវនាការនឹងគ្របដណ្តប់ទៅលើប្រធានបទចំនួនបួន មានដូចជា រចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅក្នុងអម្លុងពេលមុនការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយនានារបស់កម្ពុជាប្រជាធិតេយ្យ ស្តីពីបញ្ហាផ្សេងៗដែលបានលើកនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។

៤- នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ សហព្រះរាជអាជ្ញា មេធាវីការពារក្តី អៀង ធីរិទ្ធ មេធាវីការពារក្តី ខៀវ សំផន និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់បញ្ជីឯកសាររបស់ខ្លួនសម្រាប់ដំណាក់កាលដំបូងនៃសវនាការ។ បញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការរបស់

[2] **E1/4.1** ប្រតិចារិកនៃសវនាការបឋម ជាសាធារណៈ, ២៧ មិថុនា ២០១១, ទំព័រទី២៥ ។

សហព្រះរាជអាជ្ញា មានឯកសារចំនួន៤៧៦៨[3]។ បញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការរបស់ អៀង ធីរិទ្ធ មានឯកសារចំនួន១៩៥[4]។ បញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការរបស់ ខៀវ សំផន មានឯកសារចំនួន១២២[5]។ បញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានឯកសារចំនួនជាង៧,០០០[6]។ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ មេធាវីការពារក្តី អៀង សារី បានដាក់បញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការរបស់ខ្លួន មានឯកសារចំនួន៨[7]។ មេធាវីការពារក្តី នួន ជា មិនព្រមធ្វើតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្តល់បញ្ជីឯកសារទេ[8]។

៥- នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ បន្ទាប់ពីមានការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២[9] ទៅជាវគ្គៗតាមករណីតូចៗ និងការកំណត់ពេលសវនាការនៃការជំនុំជម្រះដំណាក់ដំបូង[10] អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ ដោយបង្គាប់ឲ្យភាគីបង្ហាញនូវឯកសារ និងវត្ថុតាងផ្សេងៗពី បញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការរបស់ខ្លួន ដែលមានបំណងចង់ឲ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធនឹងសាក្សី និងជំនាញទាំងឡាយដែលនឹងត្រូវកោះហៅនៅក្នុងរយៈពេលដំណាក់កាលដំបូងនៃសវនាការជំនុំជម្រះ មិនឲ្យហួសពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១

---

[3] **E109/4** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំឯកសារដែលទាក់ទងនឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី, ២២ កក្កដា ២០១១ និងឯកសារភ្ជាប់របស់វា **E109/4.1-4.20** (“បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់ដំណាក់កាលដំបូងនៃសវនាការ”) ។

[4] **E109** ការបញ្ជាក់ឯកសារទាំងឡាយពាក់ព័ន្ធដំណាក់ដំបូងនៃការជំនុំជម្រះពីសហមេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ, ២២ កក្កដា ២០១១ និងឯកសារភ្ជាប់របស់វា **E109.1** (“បញ្ជីឯកសាររបស់ អៀង ធីរិទ្ធសម្រាប់ដំណាក់កាលដំបូងនៃសវនាការ”) ។

[5] **E109/1** Listes de documents pour les premières phases du procès; ២២ កក្កដា ២០១១ និងឯកសារភ្ជាប់របស់វា **E109/1.1** (“បញ្ជីឯកសាររបស់ ខៀវ សំផនសម្រាប់ដំណាក់កាលដំបូងនៃសវនាការ”) ។

[6] **E109/2** បញ្ជីឯកសារ និងវត្ថុតាង របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានកែសម្រួលពាក់ព័ន្ធនឹងវគ្គទាំងបួននៃសវនាការដំបូង, ២២ កក្កដា ២០១១ និងឯកសារភ្ជាប់របស់វា **E109/2.1-2.3** (“បញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ដំណាក់កាលដំបូងនៃសវនាការ”) ។

[7] **E109/6** បញ្ជីឯកសារ និងវត្ថុតាងរបស់ អៀង សារី សម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង, ៨ សីហា ២០១១ និងឯកសារភ្ជាប់របស់វា **E109/6.2** (“បញ្ជីឯកសាររបស់ អៀង សារីសម្រាប់ដំណាក់កាលដំបូងនៃសវនាការ”) ។

[8] **E109/3** ការកត់សំគាល់អំពីឯកសារដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូង, ២២ កក្កដា ២០១១ ។

[9] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, ២២ កញ្ញា ២០១១ ។

[10] **E131** ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២, ១៨ តុលា ២០១១ ។

(“បញ្ជីឯកសារសម្រាប់វគ្គក្នុងដំណាក់ដំបូងនៃសវនាការ”)[11]។ អនុស្សរណៈបានណែនាំបន្ថែមឱ្យគូភាគី ឱ្យដាក់ការជំទាស់ណាមួយទៅនឹងឯកសារ ឬវត្ថុតាងដែលភាគីជំទាស់បានស្នើឡើង នៅក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹង។ ពាក់ព័ន្ធឯកសារ ឬវត្ថុតាង ឬប្រភេទឯកសារ ឬវត្ថុតាងដែលបានតវ៉ា ភាគីត្រូវបានបង្គាប់ឱ្យបញ្ជាក់ពីការជំទាស់ឱ្យបានជាក់លាក់ ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន៨៧(៣)[12]។

៦- នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀតថា ខ្លួននឹងស្វែងរកឱ្យមានការទទួលយកឯកសារទាំងអស់ដែលមាននៅក្នុងបញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការ របស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី[13]។ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១, សហព្រះរាជអាជ្ញា[14] មេធាវីការពារក្ដី អៀង សារី[15] និងមេធាវីការពារក្ដី អៀង ធីរិទ្ធ[16] បានដាក់បញ្ជីឯកសារសម្រាប់វគ្គដំបូងនៃសវនាការរបស់ខ្លួន។ នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវីការពារក្ដី ខៀវ សំផន បានដាក់បញ្ជីឯកសារសម្រាប់វគ្គដំបូងនៃសវនាការរបស់ខ្លួន[17]។ មកដល់ថ្ងៃត្រូវដាក់ឯកសារ មេធាវីការពារក្ដី នួន ជា មិនបានដាក់បញ្ជីឯកសារសម្រាប់វគ្គដំបូងនៃសវនាការរបស់ខ្លួនទេ។

---

[11] **E131/1** អនុស្សរណៈ, *កំណត់សំគាល់ខាងដើមលេខ១* ត្រង់ទំព័រទី១-២ ។

[12] *ដដែលដូចខាងលើ* ។

[13] **E131/1/2** បញ្ជីឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងនឹងសវនាការនៅដំណាក់កាលដំបូង (២៨ វិច្ឆិកា - ១៦ ធ្នូ ២០១១), ២៨ តុលា ២០១១ ។

[14] **E131/1/4** សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញទាំងឡាយដែលត្រូវកោះហៅក្នុងអំឡុងពេលបីសប្ដាហ៍ដំបូងនៃសវនាការ ជាមួយនឹង ឧបសម្ព័ន្ធ ក សម្ងាត់, ១ វិច្ឆិកា ២០១១ និង ឯកសារភ្ជាប់របស់វា **E131/1/4.1** (“បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់វគ្គក្នុងដំណាក់ដំបូងនៃសវនាការ”) ។

[15] **E131/1/3** បញ្ជីឯកសាររបស់ អៀង សារី សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង, ១ វិច្ឆិកា ២០១១ និង ឯកសារភ្ជាប់របស់វា (“បញ្ជីឯកសាររបស់ អៀង សារីសម្រាប់វគ្គក្នុងដំណាក់ដំបូងនៃសវនាការ”) ។

[16] **E131/1/5** បញ្ជីឈ្មោះឯកសារដែលត្រូវស្នើសុំឱ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងឈ្មោះសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលអាចនឹងត្រូវបានកោះហៅក្នុងអំឡុងពេលសវនាការរយៈពេលបីសប្ដាហ៍ដំបូង, ១ វិច្ឆិកា ២០១១ និងឯកសារភ្ជាប់របស់វា **E131/1/5.1** (“បញ្ជីឯកសាររបស់ អៀង ធីរិទ្ធសម្រាប់វគ្គក្នុងដំណាក់ដំបូងនៃសវនាការ”) ។

[17] **E131/1/6** Indications relatives aux témoins et documents des premières phases du premier procès; ២ វិច្ឆិកា ២០១១ និងឯកសារភ្ជាប់របស់វា E131/1/6.1 (“បញ្ជីឯកសាររបស់ ខៀវ សំផនសម្រាប់វគ្គក្នុងដំណាក់ដំបូងនៃសវនាការ”) ។

៧- ពាក់ព័ន្ធនឹងបញ្ហានៃការទទួលយកឯកសារ នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់ *សំណើសុំឱ្យបង្កើតប្រព័ន្ធមានប្រសិទ្ធភាពមួយ សម្រាប់ការទទួលយកភស្តុតាងជាឯកសារនៅពេលសវនាការ ("សំណើទាក់ទងនឹងភស្តុតាងជាឯកសារ")*[18]។ នៅក្នុងឯកសារនេះ សហព្រះរាជអាជ្ញាបានស្នើដល់អង្គជំនុំជម្រះសាលាដំបូង ទទួលយកភ្លាមៗនូវឯកសារណាមួយដែលបានដាក់បញ្ចូលក្នុងបញ្ជីឯកសាររបស់គូភាគីដែលមិនមានការជំទាស់ដោយភាគីដែលជំទាស់ ទុកជាភស្តុតាង; បញ្ជាក់អះអាងថា ឯកសារអាចនឹងត្រូវបានបង្ហាញដោយផ្ទាល់ និងមិនចាំបាច់ត្រូវឱ្យផ្តល់ជូនតាមរយៈសាក្សីទេ និងបែងចែកឱ្យមានវគ្គទៀងទាត់ នៅក្នុងពេលសវនាការសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ចំពោះការជំទាស់ណាមួយទៅនឹងឯកសារ។

## III. សេចក្តីជូនដំណឹង

## ក. បញ្ជីឯកសាររបស់ អៀង សារី សម្រាប់វគ្គដំបូងនៃសវនាការ

៨- បញ្ជីឯកសារសម្រាប់វគ្គដំបូងនៃសវនាការរបស់ អៀង សារី រួមមានឯកសារចំនួន៣១ ដែលក្នុងនោះឯកសារចំនួន៣០ មាននៅក្នុងសំណុំរឿង និងឯកសារមួយជាឯកសារ "ថ្មី" (មិនទាន់ដាក់នៅក្នុងសំណុំរឿងនៅឡើយ)។ គ្មានឯកសារណាមួយក្នុងចំណោមឯកសារទាំង៣១ ដែលបានស្នើឡើងដោយ អៀង សារី មាននៅក្នុងបញ្ជីឯកសារសម្រាប់វគ្គដំបូងនៃសវនាការរបស់ អៀង សារី ទេ ហើយបញ្ជីឯកសារសម្រាប់វគ្គដំបូងនៃសវនាការរបស់ អៀង សារី នេះ (ឬបញ្ជីមុនៗណាមួយដែលបានដាក់ដោយ អៀង សារី) ក៏មិនបានអនុវត្តទៅតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះដែរ ដូចជាការរៀបរាប់អំពីលក្ខណៈ ខ្លឹមសារ និងភាពពាក់ព័ន្ធនៃឯកសារដែលបានស្នើឡើងទាំងនោះ។ ទោះបីជាដូចនេះក៏ដោយ សហព្រះរាជអាជ្ញាមិនជំទាស់នឹងការទទួលយកឯកសារទាំងនេះ ដែលមាននៅក្នុងបញ្ជីឯកសារសម្រាប់ដំណាក់ដំបូងនៃសវនាការរបស់ អៀង សារី នេះទេ ដោយសារមូលហេតុផ្សេងៗដូចខាងក្រោម ។

៩- ទីមួយ គេបានកត់សំគាល់ថា ឯកសារទាំង៣១ច្បាប់ ដែលមាននៅក្នុងបញ្ជីឯកសារសម្រាប់វគ្គដំបូងនៃសវនាការរបស់ អៀង សារី មានកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានចុះហត្ថលេខាពីមុន

---

[18] **E136** សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យបង្កើតប្រព័ន្ធមានប្រសិទ្ធិភាពមួយ សម្រាប់ការទទួលយកភស្តុតាងជាឯកសារនៅពេលសវនាការ, ៣ វិច្ឆិកា ២០១១ (បានជូនដំណឹងនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១) (សំណៅច្បាប់ចម្លងត្រូវបានបញ្ជូនជាមុនគ្រាន់ជាការគួរសមជូនអង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀតនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១១) ។

និងភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវកោះហៅមកផ្តល់សក្ខីកម្ម ឯកសារភ្ជាប់នឹងកំណត់ហេតុទាំងនោះ ឬរបាយការណ៍ផ្សេងៗ ដែលបានបង្កើតដោយអង្គភាពគាំពារសាក្សីនិង កសចស ពាក់ព័ន្ធនឹងសាក្សី/ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ។ ដោយសារ លក្ខណៈ ខ្លឹមសារនិងអាគតដ្ឋាននៃឯកសារទាំងនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថាឯកសារទាំងនេះ*តាមមួយក្រឡេកមើលដំបូង* គឺមានការពាក់ព័ន្ធ និងជឿទុកចិត្តបាន អាស្រ័យហេតុនេះ គួរតែទទួលយក។

១០- ទីពីរ គេបានកត់សំគាល់ថា ឯកសារទាំង៣១ច្បាប់ ដែលមាននៅក្នុងបញ្ជីឯកសារសម្រាប់វគ្គដំណាក់ដំបូងនៃសវនាការរបស់ អៀង សារី មានឯកសារចំនួន២៣ ក៏បានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការរបស់សហព្រះរាជអាជ្ញា ឬនៅក្នុងបញ្ជីឯកសារសម្រាប់វគ្គដំបូងនៃសវនាការរបស់សហព្រះរាជអាជ្ញា[19]។ ជាការបន្ថែម មានឯកសារចំនួនប្រាំមួយ ក្នុងចំណោមឯកសារទាំងនេះដែលបានស្នើឡើងដោយ អៀង សារី បានដាក់ភ្ជាប់ជាឧបសម្ព័ន្ធនានាទៅនឹងឯកសារដែលបានបញ្ចូលក្នុងបញ្ជីឯកសារសម្រាប់ដំណាក់ដំបូងនៃសវនាការ របស់សហព្រះរាជអាជ្ញា[20]។ ទោះបីជាឧបសម្ព័ន្ធទាំងនេះមិនត្រូវបានគេចុះបញ្ជីដោយឡែកក្នុងបញ្ជីឯកសារសម្រាប់វគ្គក្នុងដំណាក់ដំបូងនៃសវនាការរបស់សហព្រះរាជអាជ្ញាក៏ដោយ ក៏ឯកសារទាំងនោះអាចឱ្យគេពិចារណាបាន ថាជាផ្នែកនៃឯកសារមេ ហេតុដូច្នេះក៏ត្រូវបានបញ្ចូលទៅក្នុងបញ្ជីទាំងនោះ។ សហព្រះរាជអាជ្ញាគាំទ្រចំពោះសំណើសុំឱ្យទទួលយកឯកសារទាំង២៩ របស់ អៀង សារី ដែលឯកសារទាំងនេះ ត្រូវបានបញ្ចូលរួចហើយនៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា។

១១- ឯកសារចំនួនពីរដែលសល់ក្នុងបញ្ជីឯកសាររបស់ អៀង សារី សម្រាប់វគ្គដំបូងនៃសវនាការ គឺជារបាយការណ៍របស់អង្គភាពជនរងគ្រោះ ទាក់ទងទៅនឹងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមាននៅក្នុងឯកសាទាំង២៩ ដែលបានរៀបរាប់នៅខាងលើ[21]។ ដូចបានកត់សម្គាល់

[19] D22/42; D22/42.3; D208/2; D247/1; D22/43; D22/43.2; D208/3; D232/59; D22/3605; D232/59.1; D91/10; D107/3; D91/3; D279/6; D279/7; D279/7.4; D234/4; D234/8; D234/15; D234/16; D166/166; D166/187 និងការស្តាប់ចម្លើយសាក្សី ជាម តុន (ហៅ ភី ភួន) ចុះកាលបរិច្ឆេទថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១០ ។

[20] D22/42.1 និង D22/42.2 គឺជាឯកសារភ្ជាប់នឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ក្លាន ហ្វិត (D22/42); D22/43.1; D22/43.3; D22/43.4 គឺជាឯកសារភ្ជាប់នឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រមាម យុន (D22/43); និង D279/7.3 គឺជាឯកសារភ្ជាប់នឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ សគឹម ល្មុត ហៅ មី, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១ (D279/7) ។

[21] D22/42/1 ទាក់ទងនឹងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ក្លាន ហ្វិត (D22/42) ។ D22/43/1 ទាក់ទងនឹងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រម៉ាម យុន (D22/43) ។

ខាងលើ ដោយសារ ចរិតលក្ខណៈ ខ្លឹមសារ និងដើមកំណើតឯកសារទាំងនោះ សហព្រះរាជអាជ្ញា សូមជូនសេចក្ដីសន្និដ្ឋានថា ឯកសារ *មួយក្រឡេកមើល* គឺមានការទាក់ទង និងគួរឱ្យជឿបាន។ ដូច្នេះ គេគួរតែទទួលយក។

១២- ពាក់ព័ន្ធទៅនឹងឯកសារថ្មីមួយដែល អៀង សារី បានស្នើ ដែលជាបទសម្ភាសន៍របស់ DC-Cam ជាមួយ ជាម តុន (ហៅ ភី ភួន) ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១០នោះ សហព្រះរាជអាជ្ញាមានសំណៅចម្លងមួយច្បាប់នៃឯកសារនេះនៅក្នុងដៃ ហើយធ្លាប់បានដាក់វាបញ្ចូលទៅក្នុងបញ្ជីឯកសារសម្រាប់វគ្គដំបូងនៃសវនាការផងដែរ[22]។ សហព្រះរាជអាជ្ញាសូមគាំទ្រការទទួលយកឯកសារនេះ ឱ្យតែកម្មវត្ថុនៃខ្លឹមសាររបស់ឯកសារនោះ គេបានចែកចាយឱ្យដល់គ្រប់ភាគីផ្សេងៗទៀតទាំងអស់ជាមុនបាន។

## ខ. បញ្ជីឯកសាររបស់ អៀង ធីរិទ្ធ សម្រាប់វគ្គដំបូងនៃសវនាការ

១៣- បញ្ជីឯកសាររបស់ អៀង ធីរិទ្ធ សម្រាប់វគ្គដំបូងនៃសវនាការ រួមមាន ៨៧ ឯកសារ[23] ដែលនៅ ក្នុងនោះ ៨០ ឯកសារ មាននៅក្នុងសំណុំរឿង ហើយ ៧ ឯកសារត្រូវបានចាត់ជាប្រភេទថ្មី។ ឯកសារទាំង ៨៧ នេះ លើកលែងតែឯកសារមួយចេញ[24] គឺមាននៅក្នុងបញ្ជីឯកសាររបស់ អៀង ធីរិទ្ធ សម្រាប់ដំណាក់កាលដំបូង។

១៤- ក្នុងចំណោម ៨០ ឯកសារនៅក្នុងសំណុំរឿងដែល អៀង ធីរិទ្ធ បានស្នើ ៤៧ ឯកសារ ក៏មានរួមបញ្ចូលនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់ដំណាក់កាលដំបូង ឬក៏មាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់វគ្គដំបូងនៃសវនាការផងដែរ[25]។ សហព្រះរាជអាជ្ញា

---

[22] *សូមអាន* បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា សម្រាប់វគ្គដំបូងនៃសវនាការ, កំណត់សម្គាល់ *ខាងលើ* លេខ១៤ ។ ៩២៨ ឯកសារ (ចុះកាលបរិច្ឆេទខុស ថ្ងៃទី២៩ តុលា ២០១០) ។

[23] បញ្ជីឯកសាររបស់ អៀង ធីរិទ្ធ សម្រាប់វគ្គដំបូងនៃសវនាការ រួមមាន ៨៨ ឯកសារមេ ។ យ៉ាងណាក៏ដោយ ឯកសារមេចំនួនពីរក្នុងចំណោមឯកសារមេទាំងនោះ បានយោងទៅដល់ឯកសារតែមួយដូចគ្នា (D199/26.2.165) ។

[24] IS 2.6 (បានកំណត់អត្តសញ្ញាណលើ បញ្ជីឯកសាររបស់ អៀង ធីរិទ្ធ សម្រាប់វគ្គដំបូងនៃសវនាការ ជា D3/ឧបសម្ព័ន្ធ C/2.6 ) ។

[25] D369/20; D248/6.1.12; D199/26.2.148; D366/7.1.514; D199/26.2.164; IS 4.7 (D222/1.3); D280/12; D231/5; D161/1.34; D366/7.1.514; D366/7.1.157 (D269/9/1.16); D369/21; D199/26.2.144; D366/7.1.350; D262.16; D222/1.17; D262.26; D199/26.2.155; D313/1.2.2; D199/26.2.23; D199/26.2.28; D366/7.1.519; D199/26.2.31; D199/26.2.153; D199/26.2.247; D366/7.1.531; D248/5.1.10; D91/20; IS 4.41 (IS 4.41/Corr-1; D222/1.15); D251/1; D366/7.1.348; D366/7.1.342; D366/7.1.535; D280/10; D280/11; D262.30; D248/6.1.11; D366/7.1.502;

សូមគាំទ្រការទទួលយកឯកសារទាំង៤៧ នេះ សូមជូនសេចក្ដីសន្និដ្ឋានថា ឯកសារ *មួយក្រឡេកម្ដែក* គឺមានការទាក់ទង និងគួរឲ្យជឿបាន។

១៥- ដោយបានពិនិត្យជាថ្មីឡើងវិញនូវឯកសារចំនួន ៣៣ ដែលសល់ ហើយដោយបានគិតពីលក្ខណៈវិនិច្ឆ័យនានាដែលបានចែងនៅក្នុងវិធាន ៨៧.៣ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាពុំបានមើលឃើញនូវមូលដ្ឋានណាមួយ សម្រាប់ជំទាស់ទៅនឹងការទទួលយកឯកសារទាំងនោះឡើយ។ ដោយឡែក សហព្រះរាជអាជ្ញាបានកត់សម្គាល់ឃើញថា ភាគច្រើននៃឯកសារទាំង៣៣ នេះ គឺជាប្រភេទមួយដែលសហព្រះរាជអាជ្ញាបានធ្វើការស្វែងរកដាក់បញ្ចូលធ្វើជាភ័ស្តុតាងផងដែរ (រួមមានកំណត់ត្រាពាណិជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ, ការបោះពុម្ពផ្សាយរបស់FBIS, របាយការណ៍របស់បណ្ដាញសារព័ត៌មានអន្តរជាតិ) ឬមួយក៏ត្រូវបានភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា។ ច្បាស់ណាស់ដែលថា ឯកសារទាំងនេះមានការទាក់ទងទៅនឹងអង្គហេតុនានានៅក្នុងរឿងនេះ ហើយមានសន្ទស្សន៍គន្លឹះនៃភាពអាចទុកចិត្តបាន ដែលអាចសម្រេចបានថាជាឯកសារសមនឹងទទួលយក។ សហព្រះរាជអាជ្ញាពិតជា មានការបម្រុងទុកខ្លះពាក់ព័ន្ធនឹងភាពទាក់ទង និងតម្លៃជាភស្តុតាងនៃឯកសារចំនួន ១០ នៅក្នុង បញ្ជីឯកសាររបស់ អៀង ធីរិទ្ធ សម្រាប់វគ្គដំបូងនៃសវនាការទាក់ទងទៅនឹងប្រតិបត្តិការរបស់អង្គការទស្សនៈពិភពលោកនៅកម្ពុជានៅមុនសម័យកម្ពុជាប្រជាធិបតេយ្យ[26]។ យ៉ាងណាក៏ដោយ ដោយបានកត់សម្គាល់ថា ឯកសារទាំងនេះត្រូវបាន កសចស ដាក់បន្ថែមទៅក្នុងសំណុំរឿងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររួចទៅហើយ។ យ៉ាងហោចណាស់ក៏គេបានចាត់ទុកថាវាមានភាពទាក់ទងបន្ទាប់បន្សំខ្លះៗដែរ នោះសហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការទទួលយកឯកសារទាំងនោះឡើយ។

១៦- ពាក់ព័ន្ធទៅនឹងឯកសារថ្មីៗចំនួន៧ ដែល អៀង ធីរិទ្ធ បានស្នើ ដែលឯកសារ២ ក្នុងចំណោមឯកសារទាំងនោះមាននៅក្នុងសំណុំរឿងរួចហើយ[27]។ សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការទទួលយកឯកសារទាំងនេះឡើយ។ បន្ថែមលើនេះ សេចក្ដីដកស្រង់នានានៃឯកសារថ្មីមួយ ដែល អៀង ធីរិទ្ធ

---

IS 13.2 (D232/8.3, D200/9.7, D279/6.1); D366/7.1.525; D366/7.1.346; D308/3.1.2; D308/3.1.1; D262.34; D3/ ឧបសម្ព័ន្ធ C/18.11 (IS 18.11); D3/ ឧបសម្ព័ន្ធ C/19.136 (IS 19.136); D3/ ឧបសម្ព័ន្ធ C/13.24 (IS 13.24) ។

[26] D306/1.3; D306/1.8: D306/1.9: D306/1.10: D306/1.11; D306/1.12 D306/1.13: D306/1.14; D306/1.18; D306/1.20 ។

[27] W. Goodfellow ។ *ទុរ្ភិក្សនៅប្រទេសកម្ពុជា* មាននៅក្នុងសំណុំរឿង ជាឯកសារ D313/1.2.263 និង D172.11 ។ T. Owen និង B. Kiernan ។ *ការទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជា* មាននៅក្នុង សំណុំរឿង ជាឯកសារ D153.12។

បានស្នើ ក៏មាននៅក្នុងសំណុំរឿងរួចហើយដែរ[28]។ ដោយបានពិនិត្យជាថ្មីឡើងវិញនូវសេចក្តីដកស្រង់ដែលអាចរកបាន សហព្រះរាជអាជ្ញាមិនបានប្រមើលមើលថាមានការជំទាស់ណាមួយទៅនឹងការទទួលយកប៉ុន្មានទំព័រ បន្ថែមនេះ ដែល អៀង ធីរិទ្ធ បានស្នើឡើយ។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាបានរក្សា គោលជំហរចុងក្រោយទុករហូតដល់ពេលដែលឯកសារទាំងនោះត្រូវបានគេធ្វើឱ្យ។ ពាក់ព័ន្ធទៅនឹងឯកសារថ្មីៗចំនួនបួនដែលនៅសល់នោះវិញ គឺមិនទំនងជាអាចរកបាននៅក្នុងសំណុំរឿង ឬនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនោះឡើយ ហើយបើមិនដូច្នោះទេ សហព្រះរាជអាជ្ញាក៏មិនទំនងជាមានសំណៅចម្លងនៃឯកសារទាំងនោះដែរ។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញារក្សាគោលជំហររបស់ខ្លួនស្តីពីឯកសារទាំងនេះ ទុករហូតដល់ពេលដែលឯកសារទាំងនោះត្រូវបានគេធ្វើឱ្យអាចរកបាន ទាំងសហព្រះរាជអាជ្ញា និងទាំងគ្រប់ភាគីទាំងអស់។ ឯកសារថ្មីៗដែល អៀង ធីរិទ្ធ បានស្នើ គឺមានរួមបញ្ចូលនៅក្នុងបញ្ជីមួយដែលបានភ្ជាប់មកជាមួយនឹងការដាក់ឯកសារនេះ ជា **ឧបសម្ព័ន្ធ** ក ។

## គ. បញ្ជីឯកសាររបស់ ខៀវ សំផន សម្រាប់វគ្គដំបូងនៃសវនាការ

១៧- បញ្ជីឯកសាររបស់ ខៀវ សំផន សម្រាប់វគ្គដំបូងនៃសវនាការ រួមមាន ៧៧ ឯកសារ[29] ដែលនៅក្នុងនោះ ៧៦ ឯកសារ មាននៅក្នុងសំណុំរឿង ឬនៅក្នុងឃ្លាំងផ្ទុកឯកសាររួម។ ឯកសារចំនួន ២៥ ក្នុងចំណោម ៧៧ ឯកសារ គឺមាននៅក្នុងបញ្ជីឯកសាររបស់ ខៀវ សំផន សម្រាប់ដំណាក់កាលដំបូង។ ក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន បានផ្តល់សំអាងថា ឯកសារបន្ថែមថ្មីនានាដែលឥឡូវនេះ បានដាក់បញ្ចូលនោះ គឺសម្រាប់គោលបំណងក្នុងការសួរតទល់សាក្សីភាគីម្ខាងទៀត[30]។

១៨- ក្នុងចំណោម ៧៧ ឯកសារដែល ខៀវ សំផន បានស្នើ ៦៦ ឯកសារក៏មានរួមបញ្ចូលនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់ដំណាក់កាលដំបូង ឬមួយក៏ក្នុងបញ្ជីឯកសាររបស់សហ

---

[28] ទំព័រ 13; 22; 27; 30; 45; 46; 66; 71 នៃសៀវភៅ *ប្រទេសកម្ពុជា៖ ទុរ្ភិក្ស និង បដិវត្តន៍ (Cambodia: Starvation and Revolution)* ដោយ Hildebrand និង Porter មាននៅក្នុងសំណុំរឿង ជាឯកសារ D178.6 និង D174.6 ។ បញ្ជីឯកសាររបស់ អៀង ធីរិទ្ធ សម្រាប់វគ្គដំបូងនៃសវនាការ ស្នើពីទំព័រ ៧-១២៤ នៃសៀវភៅនេះ ។

[29] បញ្ជីឯកសាររបស់ ខៀវ សំផន សម្រាប់វគ្គដំបូងនៃសវនាការ រួមមាន ៨០ ឯកសារមេ ។ យ៉ាងណាក៏ដោយ គេបានដាក់បញ្ចូលឯកសារមួយ ធ្វើជាឯកសារមេបីកន្លែងខុសៗគ្នា (D166/166) ហើយឯកសារមួយផ្សេងទៀត ធ្វើជាឯកសារមេពីរកន្លែងខុសៗគ្នា (IS 19.71) ។

[30] សូមអាន **E131/1/6,** Indications relatives aux témoins et documents des premières phases du premier procès ។ ថ្ងៃទី២ វិច្ឆិកា ២០១១ ត្រង់កថាខណ្ឌទី ១៨-២០ ។

ព្រះរាជអាជ្ញាសម្រាប់វគ្គដំបូងនៃសវនាការផងដែរ[31]។ បន្ថែមលើនេះ ឯកសារចំនួនបួន ក្នុងចំណោមឯកសារនានាដែល ខៀវ សំផន បានស្នើ គឺជាឧបសម្ព័ន្ធភ្ជាប់ទៅនឹងឯកសារនានា ដែលមានរួមបញ្ចូលនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា សម្រាប់វគ្គដំបូងនៃសវនាការដែរ[32]។ ដូចដែលបានកត់សម្គាល់នៅខាងដើម ទោះបីជាឧបសម្ព័ន្ធទាំងនេះមិនត្រូវបានគេចុះជាបញ្ជីផ្ទាល់ នៅក្នុងបញ្ជីនានារបស់សហព្រះរាជអាជ្ញាក៏ដោយ ក៏គេអាចពិចារណាបានថាវាជាផ្នែកមួយនៃឯកសារមេ និងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីទាំងនោះបានដែរ។ សហព្រះរាជអាជ្ញាសូមគាំទ្រការទទួលយកឯកសារទាំង ៧០ ដែល ខៀវ សំផន បានស្នើនេះ និងសូមជូនសេចក្តីសន្និដ្ឋានថា ឯកសារ *មួយក្រឡេកភ្នែក* ទាំងនេះ គឺមានការទាក់ទង និងគួរឱ្យជឿបាន។

១៩- ដោយបានពិនិត្យជាថ្មីឡើងវិញនូវឯកសារចំនួន ៧ ដែលសល់ ហើយដោយបានគិតពីលក្ខណៈវិនិច្ឆ័យនានាដែលបានចែងនៅក្នុងវិធាន ៨៧.៣ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាពុំបានមើលឃើញនូវមូលដ្ឋានណាមួយ សម្រាប់ជំទាស់ទៅនឹងការទទួលយកឯកសារទាំងនោះឡើយ។ ដោយឡែក សហព្រះរាជអាជ្ញាបានកត់សម្គាល់ឃើញថា ឯកសារចំនួនពីរក្នុងចំណោមឯកសារ ទាំងនេះ គឺជាអត្ថបទពីផ្សេងគ្នា ដែលសហព្រះរាជអាជ្ញាបានស្នើ[33] ហើយឯកសារមួយនោះ គឺជាការថតសម្លេងបទសម្ភាសន៍សាក្សីមួយរូប ដែលសហព្រះរាជអាជ្ញាបានស្នើដាក់ជូននូវកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់គាត់[34]។ ឯកសារដែលនៅសល់ចំនួនបួនទៀត ក៏ជាប្រភេទឯកសារដែលសហព្រះរាជអាជ្ញាបានស្វែងរកធ្វើការដាក់បញ្ចូលជាភ័ស្តុតាងផងដែរ (កំណត់សម្គាល់របស់កម្ពុជា

[31] D224.119; IS 21.74; D175/3.77; D234/8 (D234/8/Corr-1); D143; D279/6.12; D107/3; D366/7.1.157 (D269/9/1.16); D234/24; D369/36; IS 19.71 (D366/7.1.587); D89; D369/6; D210/5 (D248/2.2); D161/1.30(D279/6.5); D91/10; D232/59; D161/1.31(D279/6.2); D91/3; D91/30; D199/20; D222/1.17; D279/6.3; D161/1.7 (D279/6.4); D208/3; D56-Doc. 149 (D279/7.10); D161/1.9 (D279/6.13); D166/166; D247/1; D161/1.4 (D200/3.3, D279/7.5); IS 13.11 (D279/7.2); D161/1.25 (D279/6.10); D262.27; D199/26.2.172; D234/16; IS 21.142 (D279/7.7); IS 20.3; D199/26.2.38; D234/25; IS 4.41 (IS 4.41/Corr-1, D222/1.15); D201/8; D167; D161/1.21 (D279/6.9); D208/2; D201/10; D22/43 (D22/43.2); IS 21.147 (D279/7.9); D161/1.20 (D279/6.8); D22/42 (D22/42.3); D234/4; D200/3; D279/7.4; IS 13.2 (D232/8.3, D200/9.7, D279/6.1); D234/15; D91/21; IS 3.1 (D279/7.8); D161/1.13 (D279/6.7); D279/7 (D279/7/Corr-1, D279/7/Corr-2); D161/1.14 (D279/6.6); D366/7.1.584; D175/3.17; D168; IS 13.14 (D279/7.1); D279/6 (D279/6/Corr-1, D279/6/Corr-2); D248/3.3 (D189.1); D125/160 ។

[32] D279/6.11 គឺជាឯកសារភ្ជាប់ទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សគីម ល្មុត ។ ចុះថ្ងៃទី១៨ ធ្នូ ២០០៩ (D279/6) និង D279/7.3; D279/7.6; D279/7.11 គឺជាឯកសារភ្ជាប់ទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សគីម ល្មុត ។ ចុះថ្ងៃទី១៩ ធ្នូ ២០០៩ (D279/7) ។

[33] D248/6.1.2; D108/5.1 ។

[34] D369/36R ។

ប្រជាធិបតេយ្យ[35] ការប្រាស្រ័យទាក់ទងគ្នាជាមួយអន្តរជាតិ[36] និងរបាយការណ៍របស់បណ្ដាញសារព័ត៌មានអន្តរជាតិ[37]) ហើយដែលសហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា ឯកសារទាំងនេះ មានភាពទាក់ទង និងមានសូចនាករឹងមាំ នៃភាពអាចទុកចិត្តបាន។

## ឃ. បញ្ជីឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់វគ្គដំបូងនៃសវនាការ

២០- ដូចបានកត់សម្គាល់នៅខាងលើ សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឱ្យទទួលយកគ្រប់ឯកសារទាំងអស់ ដែលមាននៅក្នុងបញ្ជីឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់ដំណាក់កាលដំបូង។ បញ្ជីឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ដំណាក់កាលដំបូងនៃសវនាការ[38] ប្រមាណជា ៥.៧០០ ឯកសារ បែងចែកជា៖ ២៥ ឯកសារជាក់លាក់ពីក្នុងសំណុំរឿង មាននៅក្នុងឧបសម្ព័ន្ធ ៧(ក)(i), គ្រប់ឯកសារទាំងអស់ពីក្នុងសំណុំរឿង ដែលបានយោងនៅក្នុងផ្នែកនានានៃដីកាដំណោះស្រាយដែល ពាក់ព័ន្ធទៅនឹងប្រធានបទទាំងបួនសវនាការក្នុងដំណាក់កាលដំបូង (មាននៅក្នុងឧបសម្ព័ន្ធ ៧(ក)(ii)) (ប្រមាណជា ១.៨០០ ឯកសារ)[39], គ្រប់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទាំងអស់ (មាននៅក្នុងឧបសម្ព័ន្ធ ៧(ក)(iii)) (ប្រមាណជា ៣.៨៦៦ ឯកសារ), និង១៩ ឯកសារទៀត ត្រូវបានគេចាត់ថាជាប្រភេទឯកសារថ្មី (មាននៅក្នុងឧបសម្ព័ន្ធ ៧(ខ) និង (គ)។

២១- ក្នុងចំណោមឯកសារប្រមាណជា១៨២៥ ដែលបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធទី៧(ក)(i) និង(ii) មានឯកសារប្រមាណ១៥០០ ត្រូវបានដាក់បញ្ចូលផងដែរនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០នៃវិធានផ្ទៃក្នុង បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសំរាប់ដំណាក់

---

[35] សៀវភៅកំណត់ហេតុរបស់ យ៉េន (Yen) (ERN 00008906-20) ។ ឯកសារនេះបានកត់សម្គាល់ថា គេបានដាក់លេខ យោងឯកសារថា IS 5.5 ដោយភាន់ច្រឡំទៅលើឯកសារនេះ ។ តាមការពិត ឯកសារ IS 5.5 ជាចម្លើយសារភាពនៅស-២១ របស់ ចាន់ ចក្រី (00030985-32842) ។ សហព្រះរាជអាជ្ញា នឹងចាត់ការកែតម្រូវការភាន់ច្រឡំនេះ ហើយឱ្យគេដាក់លេខយោងឯកសារថ្មីទៅលើ សៀវភៅកំណត់ហេតុរបស់ យ៉េន (Yen) នេះ ។

[36] D199/26.2.36 ។

[37] D366/7.1.283 ឃ្លាំងផ្ទុកឯកសាររួម ឯកសារប្រមូលដោយប្រទេសស៊ុយអែដ D29273។

[38] **E109/2** បញ្ជីឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់វគ្គដំបូងនៃសវនាការ ។ កំណត់សម្គាល់*ខាងលើ* លេខ ៦ ។

[39] **E109/2.1** ឧបសម្ព័ន្ធ ៧(ក)(ii) កែប្រែ ។ មានឯកសារមេជាង ៧.០០០ នៅក្នុងបញ្ជីនេះ ។ យ៉ាងណាក៏ដោយ ឯកសារមេជាង ៥.២០០ ក្នុងចំណោមឯកសារមេទាំងនេះ ដែលត្រូវបានចុះត្រួតគ្នាដោយបានយោងទៅដល់ឯកសារនានាដែលដូចគ្នា ។

កាលទីមួយ ឬមួយក៏នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសំរាប់វគ្គដំបូងនៃសវនាការ។ សហព្រះរាជអាជ្ញាសូមគាំទ្រចំពោះការទទួលយកនូវឯកសារទាំងនេះ ហើយសូមលើកជាយោបល់ថា ឯកសារទាំងនេះគឺជាឯកសារដែលមានការជាប់ទាក់ទងនិងដែលអាចឲ្យជឿទុកចិត្តបាន *ដោយគ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង*។

២២- ក្នុងចំណោមឯកសារប្រមាណជា៣២៥ ដែលបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធទី៧(ក)(i) និង(ii) មិនមាននៅក្នុងបញ្ជីណាមួយរបស់សហព្រះរាជអាជ្ញាទេ មានឯកសារចំនួនជាង១០០ គឺជាពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬឯកសារដែលពាក់ព័ន្ធ (ដូចដែលលើកឡើងខាងក្រោមនេះ) និងឯកសារដែលនៅសល់ដែលជាប្រភេទឯកសារមួយ ដែលសហព្រះរាជអាជ្ញាបានខិតខំទាមទារសុំដើម្បីឲ្យចូលជាភ័ស្តុតាង(ការប្រាស្រ័យទាក់ទងគ្នានានារបស់កម្ពុជាប្រជាធិបតេយ្យ, កំណត់ហេតុនៃការសួរចម្លើយនានារបស់ កសចស, ការប្រាស្រ័យទាក់ទងនានាជាមួយអន្តរជាតិ, ការបោះផ្សាយនានាអំពីការសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងការសិក្សាស្រាវជ្រាវនានា)។ ដោយចងចាំទុកនៅក្នុងចិត្តអំពីលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុងវិធាន៨៧.៣ នៃវិធានផ្ទៃក្នុង ហើយដែលតាមពិតទៅថាឯកសារទាំងនេះត្រូវបាន កសចស ដាក់យោងសម្រាប់គាំទ្រចំពោះការរកឃើញទាំងឡាយដែលនៅក្នុងដីកាដំណោះរួចហើយ។ សហព្រះរាជអាជ្ញារកមិនឃើញថាមានមូលដ្ឋានអ្វី ដើម្បីជំទាស់ចំពោះការទទួលយកនូវឯកសារទាំងនេះឡើយ។

២៣- ចំណែកពាក្យសុំចំនួន៣៨៦៦ របស់ដើម្បណ្តឹងរដ្ឋប្បវេណីវិញ គឺត្រូវបានគេកត់សំគាល់ថា ភាគធំនៃឯកសារទាំងនេះ កំពុងត្រូវបានធ្វើចំណាត់ថ្នាក់នៅក្នុងពេលបច្ចុប្បន្ននេះ ថាជាការសំងាត់បំផុត ដោយសារតែសេចក្តីសម្រេចស្តីពីវិធានការការពារចំពោះជនទាំងនេះ មិនទាន់ត្រូវមបានធ្វើឡើងនៅឡើយ។ ដូចដែលមានចែងនៅក្នុងចម្លើយតបរួមរបស់ខ្លួនទៅនឹងញត្តិស្នើសុំរបស់ អៀង សារី និង អៀង ធីរិទ្ធ ទាក់ទងអំពីសិទ្ធិក្នុងការចូលទៅពិនិត្យមើលនូវឯកសារដែលសំងាត់បំផុតទាំងនេះ។ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសម្រេច ស្តីពីវិធានការការពារដែលដើមបណ្តឹងរដ្ឋប្បវេណីនានាបានស្នើ ហើយធ្វើចំណាត់ថ្នាក់ជាថ្មីឡើងវិញលើឯកសារទាំងនេះ ដើម្បីឲ្យឯកសារទាំងនោះមានសម្រាប់ឲ្យភាគីនានាអាចរកបាន ក្នុងទម្រង់ទាំងមូល ឬក្នុងទម្រង់

ដែលមានការកោសលុបខ្លះ[40]។ ដោយសារតែសិទ្ធិក្នុងការចូលទៅពិនិត្យមើលឯកសារ ត្រូវបានអនុញ្ញាតទៅឱ្យភាគីនានាផ្សេងទៀតនោះ គឺសហព្រះរាជអាជ្ញាការគាំទ្រចំពោះការទទួលយកនូវពាក្យសុំនានារបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី។

២៤- ចំពោះឯកសារចំនួន១៨ដែលត្រូវបានចាត់ចូលជាប្រភេទថ្មី នៅក្នុងឧបសម្ព័ន្ធទី៧(ខ)នោះវិញ ត្រូវបានគេកត់សំគាល់ថា បច្ចុប្បន្ននេះ រាល់ឯកសារទាំងអស់នោះ គឺមាននៅក្នុងសំណុំរឿង ដែលងាយរកបាន[41]។ សហព្រះរាជអាជ្ញាបានពិនិត្យមើលឡើងវិញនូវឯកសារទាំងនេះ និងដោយបានចងចាំទុកនៅក្នុងចិត្តអំពីលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុងវិធាន៨៧.៣នៃវិធានផ្ទៃក្នុងនោះ គឺមិនឃើញមានមូលដ្ឋានអ្វី ដើម្បីជំទាស់ទៅនឹងការទទួលយកនូវឯកសារទាំងនេះឡើយ។

២៥- ឯកសារថ្មីដែលត្រូវបានដាក់ធ្វើជាបញ្ជីភ្ជាប់នៅក្នុងឧបសម្ព័ន្ធ៧(ខ)នោះ គឺជាហ្វីលនៃខ្សែភាពយន្តឯកសារដែលមានចំណងជើងថា *សត្រូវរបស់ប្រជាជន*[42] ត្រូវបានសហព្រះរាជអាជ្ញាធ្វើការពិនិត្យឡើងវិញ ហើយបានគាំទ្រចំពោះការដាក់បញ្ចូលឯកសារទាំងនេះជាភ័ស្តុតាង ដោយសារតែឯកសារទាំងនេះកំពុងតែត្រូវបានដាក់បន្ថែមចូលក្នុងសំណុំរឿង ឬម៉្យាងទៀតត្រូវបានបើកសម្រាប់ឱ្យគ្រប់ភាគីទាំងអស់អាចរកបាន។ តាមពិត សហព្រះរាជអាជ្ញាបានជូនដំណឹងអំពីបំណងរបស់ខ្លួនចង់ដាក់នូវសេចក្តីដកស្រង់ចេញពីឯកសារនេះ (ដែលបានមកពីគេហទំព័រដែលមានអាសយដ្ឋាន៖

[40] E118/2 ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ អៀង សារី និងញត្តិរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងសិទ្ធិក្នុងការចូលពិនិត្យមើលឯកសារដែលជាការសំងាត់បំផុត ចុះថ្ងៃទី៣ តុលា ២០១១ នៅត្រង់កថាខណ្ឌទី២៨-៣១។

[41] ឯកសារពីលេខ១ដល់១៤នៅក្នុងឧបសម្ព័ន្ធទី៧(ខ) គឺជាចម្លើយរបស់សាក្សីនានា ដែលមានសំរាប់ឱ្យងាយរកបាននៅក្នុងសំណុំរឿង លេខ E9/32.2.1 – 14 ។ ឯកសារលេខ១៥នៅក្នុងឧបសម្ព័ន្ធទី៧(ខ) គឺជាហ្វីលខ្សែភាពយន្តឯកសារដែលផលិតដោយ Aronowitsc និង Lindberg និងដែលនៅក្នុងសំណុំរឿង ក្នុងនាមជាឯកសារលេខ E9/109/2.3R ។ ចម្លើយទាំងអស់ប៉ុន្តែមានចម្លើយមួយនៅក្នុងចម្លើយទាំងនេះ បច្ចុប្បន្ននេះគឺមានស្រាប់អាចឱ្យរកបានតែជាភាសាខ្មែរប៉ុណ្ណោះ។ ឯកសារលេខ ១១ (E9/32.11) បច្ចុប្បន្ននេះមានស្រាប់សំរាប់ឱ្យរកបានតែជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ ឯកសារលេខ១៦នៅក្នុងឧបសម្ព័ន្ធទី៧(ខ) គឺជាឯកសារដោយលោកSaidnattar ដែលបច្ចុប្បន្ននេះមានស្រាប់សំរាប់ឱ្យអាចរកបាននៅក្នុងនាមជាឯកសារលេខ (E109/2.3R)។ ឯកសារលេខ១៧នៅក្នុងឧបសម្ព័ន្ធទី៧(ខ) គឺជាសៀវភៅដែលនិពន្ធដោយលោក Raoul Marc Jennar ដែលបច្ចុប្បន្ននេះមាននៅក្នុងនៅក្នុងសំណុំរឿង (ជាភាសាបារាំងតែប៉ណ្ណោះ) ក្នុងនាមជាឯកសារលេខ (E109/2.3.1)។ ឯកសារលេខ១៨ នៅក្នុងឧបសម្ព័ន្ធទី៧(ខ) គឺជាចម្លើយសាក្សី(ដែលគ្មានដាក់កាលបរច្ឆេទ)ឈ្មោះ ជូ គឹមឡេង (CHOU KoemLeg) ដោយផ្អែកលើមូលដ្ឋាននៃ សេចក្តីពីពណ៌នាដោយសង្ខេប ដែលមាននៅក្នុងបញ្ជីរបស់ ភាគីដមបណ្តឹងរដ្ឋប្បវេណី នេះគឺហាក់បីដូចជាស្របគ្នាជាមួយនឹងចម្លើយមួយចុះថ្ងៃទី២៨ កុម្ភៈ ២០១១ ដែលមានអាចឱ្យងាយរកបាននៅក្នុងសំណុំរឿង ក្នុងនាមជាឯកសារលេខ E9/32.2.២៨។ បច្ចុប្បន្ននេះគឺមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ។

[42] ត្រូវបានដាក់ក្នុងបញ្ជីជាលេខរៀងទី១ នៅក្នុងឧបសម្ព័ន្ធ៧(គ)។

www.youtube.com) នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងអនុលោមតាមវិធាន៨៧(៤)[43]។ សហព្រះរាជអាជ្ញាបានប៉ុនប៉ងដើម្បីឱ្យទទួលបាននូវច្បាប់ចម្លងទាំងមូលនៃឯកសារនោះ នៅពេលណាមួយ ហើយភ្លាមៗបន្ទាប់ពីសហព្រះរាជអាជ្ញារកបាន សហព្រះរាជអាជ្ញានឹងស្នើសុំឱ្យដាក់បញ្ចូលឯកសារទាំងនេះជាភ័ស្តុតាង អនុលោមតាមវិធាន៨៧(៤)។

២៦- ឯកសារថ្មីៗទាំងអស់ដែលបានស្នើឡើងដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដាក់បញ្ចូល នៅក្នុងបញ្ជីភ្ជាប់ជាមួយនឹងឯកសារដែលដាក់ជូននេះ ក្នុងនាមជា**ឧបសម្ព័ន្ធ** ក។

២៧- ជាសេចក្តីសង្កេតចុងក្រោយមួយទៅឡើឯកសារដែលបានស្នើឡើងដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានគេធ្វើការកត់សំគាល់ថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់អំពីការជាប់ទាក់ទងគ្នានៃឯកសារចំនួនប្រាំក្នុងចំណោមឯកសារដែលនៅក្នុងឧបសម្ព័ន្ធទី៧(ក)(i)[44] និងឯកសារចំនួន១២ ក្នុងចំណោមឯកសារនានាដែលនៅក្នុងឧបសម្ព័ន្ធទី៧(ខ)[45]ថាជាឯកសារដែលកំពុងតែ(មានតែមួយគត់ ឬដែលមានផ្នែកខ្លះ) "ផ្ទុយទៅនឹង"សេចក្តីសន្និដ្ឋានរបស់កថាខណ្ឌទី១៤២៩ នៃដីកាដំណោះស្រាយដែលទាក់ទងនឹងឧក្រិដ្ឋកម្មរំលោភសេពសន្ថវៈ។ រីឯសហព្រះរាជអាជ្ញាវិញមិនបានស្នើសុំឱ្យដាក់បញ្ចូលនូវឯកសារទាំងនេះ ដើម្បីគោលបំណងនេះទេ ដោយធ្វើការកត់សំគាល់ថា ជនជាប់ចោទមិនត្រូវបានចោទប្រកាន់អំពីការប្រើនូវឧក្រិដ្ឋកម្មរំលោភសេពសន្ថវៈ (ក្រៅពីបរិបទស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ដើម្បីអនុវត្តនូវផែនការឧក្រិដ្ឋរួមនោះទេ សហព្រះរាជអាជ្ញាជឿថា ឯកសារទាំងនេះ គឺមានបរិបទដែលជាប់ទាក់ទងគ្នាជាមួយនឹងអង្គហេតុដែលមានបញ្ហា ហើយហេតុនេះ ជាការសមស្របគឺត្រូវតែទទួលយកនូវឯកសារទាំងនេះ។

[43] ឯកសារលេខ E93/7 សំណើសុំរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំឱ្យស្តាប់បចម្លើយរបស់អ្នកជំនាញ២ (ពីរ)នាក់ និងសាក្សី១៣ (ដប់បី) នាក់បន្ថែមទៀតនៅក្នុងអម្លុងដំណាក់កាលទីមួយនៃសវនាការជំនុំជម្រះក្តី និងសេចក្តីជូនដំណឹងអំពីគោលបំណងឱ្យចង់ដាក់ខ្សែវីដេអូខ្លីៗចំនួនប្រាំពីរខ្សែដែលទាក់ទងនឹង នួន ជា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូ អនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី៥ កក្កដា២០១១ ។ ខ្សែវីដេអូខ្លីៗទាំង ៧ខ្សែនេះ សព្វថ្ងៃនេះគឺមានជូនសំរាប់ងាយរកបាន នៅក្នុងសំណុំរឿង ក្នុងនាមជាឯកសារលេខ E93/7.3R ។

[44] ឯកសារលេខ D190 (ឧបសម្ព័ន្ធ ក)។ ឯកសារលេខ D190 (ឧបសម្ព័ន្ធ ខ)។ ឯកសារលេខ D190 (ឧបសម្ព័ន្ធ គ)។ ឯកសារលេខ D125/91 ឯកសារលេខ D125/123 ដែលត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ ៧(ក)(i)។

[45] ឯកសារដែលដាក់លេខពី១ ដល់១១ និង១៣ ដែលនៅក្នុងឧបសម្ព័ន្ធ៧(ខ)។

### ង. សេចក្តីសង្កេតជាទូទៅ ចំពោះចម្លើយជាលាយលក្ខណ៍អក្សរ

២៨- គេបានកត់សំគាល់ថា គ្រប់ភាគីទាំងអស់បានដាក់បញ្ចូលនូវចម្លើយជាលាយលក្ខណ៍អក្សរ កាលពីមុនៗរបស់សាក្សី ឬរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនានា នៅក្នុងបញ្ជីឯកសាររបស់ខ្លួន។ មានចម្លើយមួយចំនួនធំ ក្នុងចំណោមចម្លើយទាំងនេះ គឺមិនទាក់ទងទៅនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទទាំងនេះ ឬទៅនឹងអ្នកនៅក្រោមបង្គាប់របស់ពួកគេនោះទេ។ ក៏ប៉ុន្តែផ្ទុយទៅវិញ គឺជាប់ទាក់ទងទៅនឹងព្រឹត្តការណ៍នានានៅតាមតាំងឧក្រិដ្ឋកម្ម ផលប៉ះពាល់នៃឧក្រិដ្ឋទាំងនេះទៅលើជនរងគ្រោះនានា និងបញ្ហាដែលពាក់ព័ន្ធផ្សេងទៀត ដូចជាគោលនយោបាយរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងគ្នា និងអត្ថិភាពនៃផែនការឧក្រិដ្ឋកម្មរួម។ សហព្រះរាជអាជ្ញាបញ្ជាក់សារជាថ្មីឡើងវិញនូវសេចក្តីសន្និដ្ឋានកាលពីមុនៗរបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការទទួលយកនូវចម្លើយជាលាយលក្ខណ៍អក្សរនានា កាលពីមុនដែលមិនបានបង្ហាញជាភ័ស្តុតាងស្តីពីអំពើ ឬការប្រព្រឹត្តិរបស់ជនជាប់ចោទណាម្នាក់ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នោះមិនចាំបាច់កោះហៅសាក្សីឲ្យមកផ្តល់សក្ខីកម្មនៅក្នុងពេលសវនាការ[46]។ ករណីបើសិនជាចម្លើយនោះជាប់ទាក់ទងទៅនឹងអំពើ ឬការប្រព្រឹត្តិរបស់ជនជាប់ចោទណាម្នាក់ឬទៅនឹងបញ្ហាស្នូលណាមួយនៅក្នុងករណីនេះ ជនជាប់ចោទមានសិទ្ធិក្នុងការតទល់ជាមួយសាក្សីបាន។ ក៏ប៉ុន្តែ បើសិនជាជនជាប់ចោទសម្រេចចិត្តថា មិនអនុវត្តនូវសិទ្ធិនេះទេនោះ អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកចម្លើយនេះបាន ដោយមិនបាច់តម្រូវឲ្យសាក្សីចូលមកបង្ហាញខ្លួនដើម្បីឲ្យខាងភាគីបដិបក្ខសួរដេញដោលនោះឡើយ។

## IV. សេចក្តីសន្និដ្ឋាន និង សំណើ

២៩- អាស្រ័យដោយមូលហេតុដូចបានលើកឡើងខាងលើ សហព្រះរាជអាជ្ញាសូមធ្វើការជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា សហព្រះរាជអាជ្ញា ៖

[46] ឯកសារលេខ E96 សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨២ទាក់ទងនឹងការទទួលយកចម្លើយសាក្សីនានាជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង ឯកសារលេខ E96/6 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបនានាស្តីពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ សីហា ២០១១។

(១) មិនជំទាស់ទៅនឹងការទទួលយកនូវឯកសារណាមួយក្នុងចំណោមឯកសារដែលបានស្នើសុំ ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារដែលក្រុមមេធាវីការពារក្ដីរបស់ អៀង សារី ឬ ខៀវ សំផន បានដាក់ជូន ដោយឯកសារថ្មីមួយដែលត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីរបស់ អៀង សារី ត្រូវតែរកបានជាមុន សម្រាប់ឲ្យភាគីផ្សេងៗទៀត។

(២) រក្សានូវជំហររបស់ខ្លួនទាក់ទងទៅនឹងឯកសារ"ថ្មី"ចំនួន៥ ដែលបានស្នើឡើង បានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារដែលដាក់ជូនដោយក្រុមមេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ រហូតដល់ពេល ឯកសារទាំងអស់រកបាន។

(៣) ម៉្យាងទៀត មិនជំទាស់ចំពោះការទទួលយកនូវឯកសារដែលបានស្នើឡើងណាមួយ ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារនានាដែលដាក់ជូនដោយមេធាវីការពារក្ដី អៀង ធីរិទ្ធ (រួមមានប្រភេទឯកសារថ្មីចំនួន២ ថាជាឯកសារថ្មី ដែលតាមពិតមាននៅក្នុងសំណុំរឿងរួចហើយ) និង

(៤) មិនជំទាស់ចំពោះការទទួលយកនូវឯកសារដែលបានស្នើឡើងណាមួយ ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារនានា ដែលដាក់ជូនដោយសហមេធាវីនាំមុខនៃដើមបណ្ដឹងរដ្ឋប្បវេណី ថាជាឯកសារថ្មីមួយដែលបានស្នើឡើង ហើយពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវរកបានជាមុន សម្រាប់ឲ្យភាគីផ្សេងៗទៀតងាយស្រួលរក។

៣០. លើសពីនេះ សហព្រះរាជអាជ្ញាសូមស្នើថា ដោយគ្មានការទទួលបាននូវជំទាស់ណាមួយពីភាគីណាមួយផ្សេងទៀតនោះ ឯកសារទាំងឡាយដែលសហព្រះរាជអាជ្ញាមិនបានធ្វើការជំទាស់នោះ គួរតែត្រូវបានទទួលយកធ្វើជាភស្តុតាងភ្លាម ហើយលុះត្រាតែឯកសារទាំងនោះត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងតុលាការតែប៉ុណ្ណោះ។ វិធីសាស្ត្រនេះ ត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញានៅក្នុង*សំណើរបស់ខ្លួនថ្មីៗនេះទាក់ទងនឹងភស្តុតាងជាឯកសារ*[47]។ ដូចដែលបានកត់សំគាល់នៅក្នុងសំណើនេះស្រាប់ ការកំណត់អត្តសញ្ញាណឯកសារនៅក្នុងតុលាការ ឧទាហរណ៍ដូចជា ការយោងទៅលើលេខរបស់ឯកសារ និង/ឬទៅលើការរៀបរាប់ដោយត្រួសៗ គឺបំពេញទៅតាម

[47] កំណត់សំគាល់លេខ១៨ *ពីខាងដើម*។

លក្ខខណ្ឌតម្រូវនៅក្នុងវិធាន៨៧(២)នៃវិធានផ្ទៃក្នុង ដែលថា ភ័ស្តុតាងត្រូវតែ "ដាក់នៅចំពោះមុខអង្គជំនុំជម្រះ" និងនៅមុនពេលដែលភាគីនានាអាចមានឱកាស ក្នុងការជំទាស់នឹងឯកសារទាំងនេះ គឺបំពេញទៅតាមលក្ខខណ្ឌតម្រូវនៅក្នុងវិធាន៨៧(២) ដែលចែងថា ភ័ស្តុតាងត្រូវតែ "ដាក់ឱ្យស្ទួរដេញដោល"[48]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |

[48] ដូចគ្នានឹងខាងលើ ត្រង់កថាខណ្ឌទី៧-៨។